# ឧបសម្ព័ន្ធ ៣
# វិញ្ញាបនបត្រដើមកំណើត

១. ផលិតផលទទួលបានពី (ឈ្មោះក្រុមហ៊ុន អាសយដ្ឋាន ប្រទេសរបស់អ្នកនាំចេញ)

២. ផលិតផលត្រូវបានបញ្ជូនទៅ (ឈ្មោះ អាសយដ្ឋាន ប្រទេសរបស់អ្នកទទួលទំនិញ)

លេខយោង.

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន
វិញ្ញាបនបត្រដើមកំណើត
(រួមបញ្ចូលទាំង សេចក្តីប្រកាស និងវិញ្ញាបនបត្រ)

សូមពិនិត្យមើលកំណត់សម្គាល់នៅទំព័រខាងខ្នង

៣. មធ្យោបាយដឹកជញ្ជូន និងផ្លូវ (តាមដែលដឹង)

កាលបរិច្ឆេទចេញដំណើរ

ឈ្មោះរបស់នាវា/យន្តហោះ -ល-

កំពង់ផែផ្ទេរទំនិញ

៤. សម្រាប់ការប្រើប្រាស់ជាផ្លូវការ

☐ នផ្តល់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ

☐ មិនត្រូវបានផ្តល់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ (សូមបញ្ជាក់នូវហេតុផល)

.....................................................................................

ហត្ថលេខា របស់ហត្ថលេខីដែលទទួលបានសិទ្ធិ នៃប្រទេសនាំចូល

| ៥. ចំនួនទំនិញ | ៦. ម៉ាកសញ្ញា និងចំនួនកញ្ចប់ | ៧. ចំនួន និងប្រភេទនៃកញ្ចប់, ការពិពណ៌នានៃផលិតផល (រួមមាន បរិមាណ ប្រសិនបើមាន និង លេខកូដ HS ក្នុងកម្រិត ៦ ខ្ទង់) | ៨. លក្ខណៈវិនិច្ឆ័យដើមកំណើត (សូមពិនិត្យមើលកំណត់សម្គាល់នៅទំព័រខាងខ្នង) | ៩. ទម្ងន់សរុប ឬទម្ងន់សុទ្ធឬបរិមាណផ្សេងទៀត និងតម្លៃ FOB នៅពេលដែលលក្ខណៈវិនិច្ឆ័យដើមកំណើតសមាសភាគតម្លៃតំបន់ (RVC) ត្រូវបានប្រើប្រាស់ | ១០. លេខ និងកាលបរិច្ឆេទវិក្កយបត្រ |
|---|---|---|---|---|---|
| | | | | | |

១១. សេចក្តីប្រកាសរបស់អ្នកនាំចេញ

ខាងក្រោមនេះជាហត្ថលេខាប្រកាសថា ព័ត៌មានលម្អិត និងសេចក្តីប្រកាសខាងលើពិតជាត្រឹមត្រូវ ហើយផលិតផលទាំងអស់ត្រូវបានផលិតក្នុង

.....................................................................................

(ប្រទេស)

ហើយដែលត្រូវបានអនុលោមតាមលក្ខខណ្ឌតម្រូវសម្រាប់ផលិតផលទាំងនេះដូចមានចែងក្នុងវិធានដើមកំណើតក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន សម្រាប់ផលិតផលទាំងឡាយណាដែលត្រូវបាននាំចេញទៅ

.....................................................................................

(ប្រទេសនាំចូល)

.....................................................................................

ទីកន្លែង និងកាលបរិច្ឆេទ ហត្ថលេខា
របស់ហត្ថលេខីដែលទទួលបានសិទ្ធិ

១២. ការបញ្ជាក់វិញ្ញាបនបត្រ

ផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យដែលបានអនុវត្ត ខ្ញុំសូមធ្វើការបញ្ជាក់ថា សេចក្តីប្រកាសរបស់អ្នកនាំចេញគឺត្រឹមត្រូវ

.....................................................................................

ទីកន្លែង និងកាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់អាជ្ញាធរដែលទទួលបានសិទ្ធិ

១៣.

- ☐ ត្រូវបានចេញដោយប្រតិសកម្ម
- ☐ ទំនិញតាំងពិព័រណ៍
- ☐ វិក្កយបត្រចេញដោយភាគីទីបី

## កំណត់សម្គាល់នៅទំព័រខាងខ្នង

១. ភាគីដែលទទួលយកទម្រង់នេះគឺក្នុងគោលបំណងអនុវត្តប្រព្រឹត្តកម្មអនុគ្រោះពន្ធគយក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA): កម្ពុជា, ចិន។

២. លក្ខខណ្ឌ៖ លក្ខខណ្ឌចម្បងសម្រាប់អនុវត្តប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ ក្រោមកិច្ចព្រមព្រៀង CCFTA គឺផលិតផលដែលបញ្ជូនទៅឱ្យភាគីម្ខាងទៀត។

(ក) ត្រូវតែដូចគ្នាទៅនឹងការពិពណ៌នាអំពីផលិតផល ដែលមានសិទ្ធិទទួលបានសម្បទានពន្ធគយនៅក្នុងប្រទេសជាគោលដៅនោះ;

(ខ) ត្រូវតែមានអនុលោមភាពជាមួយបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់នៃជំពូកវិធានដើមកំណើតក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ដែលមានរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។

៣. លក្ខណៈវិនិច្ឆ័យដើមកំណើត៖ សម្រាប់ទំនិញនីមួយៗដែលបានពិពណ៌នានៅក្នុងប្រអប់ទី ៧ នៃទម្រង់នេះ លក្ខណៈវិនិច្ឆ័យដើមកំណើតដែលបានបំពេញ ត្រូវបង្ហាញក្នុងប្រអប់ ៨ តាមរបៀបក្នុងតារាងខាងក្រោម៖

| លក្ខណៈវិនិច្ឆ័យដើមកំណើត | បង្ហាញក្នុងប្រអប់ ៨ |
|---|---|
| (ក) ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុងស្របតាមវាក្យខណ្ឌ(ក) នៃមាត្រា ២ នៃផ្នែក ក នៃជំពូកវិធានដើមកំណើតក្រោមកិច្ចព្រម-ព្រៀង CCFTA | WO |
| (ខ) ទំនិញដែលផលិតក្នុងភាគីមួយទាំងស្រុងពីវត្ថុធាតុមានដើមកំណើតមកពីបណ្តាភាគីនានា ស្របតាមវាក្យខណ្ឌ (ក) នៃមាត្រា ២ នៃផ្នែក ក នៃជំពូកវិធានដើមកំណើត ក្រោមកិច្ចព្រមព្រៀង CCFTA | PE |
| (គ) ទំនិញដែលផលិតពីវត្ថុធាតុមិនមានដើមកំណើតក្នុងភាគីមួយ ស្របតាមកថាខណ្ឌ ១ នៃមាត្រា ៤ នៃផ្នែក ក នៃជំពូកវិធានដើមកំណើត ក្រោមកិច្ចព្រមព្រៀង CCFTA | |
| - សមាសភាគតម្លៃតំបន់ | ចំនួនភាគរយជាក់ស្តែងនៃសមាសភាគតម្លៃតំបន់ CCFTA, ឧទាហរណ៍ "40%" |
| - ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ក្នុងកម្រិត ៤ខ្ទង់ | CTH |
| ទំនិញដែលបានបំពេញតាមវិធានផលិតផលជាក់លាក់ (PSR)ក្នុងឧបសម្ព័ន្ធ ២ នៃជំពូកវិធានដើមកំណើត ក្រោមកិច្ចព្រមព្រៀង CCFTA | PSR |

៤. ទំនិញនីមួយៗត្រូវតែមានលក្ខណៈសម្បត្តិ៖ សូមកត់សម្គាល់ថា រាល់ផលិតផលទាំងអស់ដែលមាននៅក្នុងការដឹកជញ្ជូនត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រៀងៗខ្លួន។ នេះគឺទាក់ទងជាពិសេស នៅពេលទំនិញស្រដៀងគ្នា ទំហំខុសគ្នា ឬគ្រឿងបន្លាស់ ត្រូវបានដឹកជញ្ជូន។

៥. ការពិពណ៌នាអំពីផលិតផល៖ ការពិពណ៌នាអំពីផលិតផលក្នុងប្រអប់ ៧ ត្រូវតែមានលក្ខណៈលំអិតគ្រប់គ្រាន់ដើម្បីឱ្យផលិតផលនេះត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីគយដែលត្រួតពិនិត្យពួកគេ។

៦. លេខកូដតាមប្រព័ន្ធសុខដុមនីយកម្ម (ចំនួន ៦ ខ្ទង់) នៃភាគីនាំចូល ក្នុងប្រអប់ ៧ ត្រូវកំណត់ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិស្តីពីប្រព័ន្ធសុខដុមនីយកម្មបរិយាយចំណាត់ថ្នាក់ទំនិញ និងលេខកូដទំនិញ និងវិសោធនកម្មបន្តបន្ទាប់នៃអនុសញ្ញានេះ។

៧. "អ្នកនាំចេញ" ក្នុងប្រអប់ ១ និង ១១ អាចរាប់បញ្ចូលទាំងរោងចក្រផលិត ឬផលិតករ។ រោងចក្រផលិតអាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើតក្នុងករណីដែលរោងចក្រផលិតត្រូវបានតម្រូវឱ្យផ្តល់សិទ្ធិទៅភ្នាក់ងារ ឬភាគីដទៃដើម្បីជាតំណាងនាំចេញជំនួសរោងចក្រផលិតនោះ។ ក្នុងករណីដូចនេះ រោងចក្រផលិតអាចធ្វើការប្រកាសក្នុងប្រអប់ ១១ និងត្រូវបង្ហាញឈ្មោះនិងអាសយដ្ឋានអ្នកនាំចេញក្នុងប្រអប់ ៧។

៨. សម្រាប់ប្រើប្រាស់ដោយមន្ត្រីមានសមត្ថកិច្ច៖ អាជ្ញាធរគយនៃភាគីនាំចូលត្រូវគូស (√) ក្នុងប្រអប់ជាក់ស្តែង ក្នុងប្រអប់ ៤ ថាប្រព្រឹត្តកម្មអនុគ្រោះពន្ធត្រូវបានឬមិនត្រូវបានផ្តល់ឱ្យ។

៩. វិក្កយបត្រចេញដោយភាគីទីបី៖ ក្នុងករណីដែលវិក្កយបត្រត្រូវបានចេញដោយភាគីដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ប្រអប់ "វិក្កយបត្រចេញដោយភាគីទីបី" គឺតម្រូវឱ្យមានគូស (√) ហើយលេខវិក្កយបត្រត្រូវបង្ហាញនៅក្នុងប្រអប់ ១០។ ព័ត៌មានដូចជា ឈ្មោះ និងប្រទេសរបស់ក្រុមហ៊ុនដែលចេញវិក្កយបត្រត្រូវបង្ហាញក្នុងប្រអប់ ៧។

១០. ការតាំងពិព័រណ៍៖ ក្នុងករណីផលិតផលត្រូវបានផ្ញើពីភាគីនាំចេញសម្រាប់តាំងពិព័រណ៍នៅភាគីមួយទៀត ហើយត្រូវបានលក់សម្រាប់នាំចូលទៅកាន់ភាគីមួយទៀតក្នុងពេល ឬក្រោយពេលតាំងបង្ហាញនោះស្របតាមវិធាន ២០ នៃ ផ្នែក ខ នៃវិធានដើមកំណើតសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, ប្រអប់ "ទំនិញតាំងពិព័រណ៍" ក្នុងប្រអប់ ១៣ គឺតម្រូវឱ្យមានគូស (√) ហើយឈ្មោះនិងអាសយដ្ឋានការតាំងពិព័រណ៍ត្រូវបង្ហាញក្នុងប្រអប់ ២។

១១. ត្រូវបានចេញដោយប្រតិសកម្ម៖ ក្នុងករណីលើកលែងមួយចំនួន ដែលកើតឡើងដោយសារកំហុស, ការលុប, ឬហេតុផលសមស្របផ្សេងទៀតដោយអចេតនា, វិញ្ញាបនបត្រដើមកំណើតអាចត្រូវបានចេញដោយប្រតិសកម្មស្របតាមវិធាន ១១ នៃ ផ្នែក ខ នៃវិធានដើមកំណើតសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។ ប្រអប់ "ត្រូវបានចេញដោយប្រតិសកម្ម" ក្នុងប្រអប់ ១៣ គឺតម្រូវឱ្យគូស (√) ដោយអេឡិចត្រូនិក ឬដោយការវាយពុម្ពជាមួយនឹងព័ត៌មានដទៃទៀតនៅក្នុងវិញ្ញាបនបត្រដើមកំណើត។ ក្នុងករណីដែលប្រអប់ "ត្រូវបានចេញដោយប្រតិសកម្ម" ក្នុងប្រអប់ ១៣ មិនអាចគូសបានដោយអេឡិចត្រូនិក ឬដោយការវាយពុម្ព នោះតម្រូវឱ្យមានប្រថាប់ត្រា "ISSUED RETROACTIVELY" នៅលើវិញ្ញាបនបត្រដើមកំណើតទំនិញនោះ។